# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០ អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលខ្លឹមសារនៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ១៥ ដល់លេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- យោងអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការកែសំរួលខ្លឹមសារនៃអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- យោងសេចក្តីជូនដំណឹងលេខ១១៦៩ សជណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១០ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៦
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**មាត្រា១:** បន្ថែមក្នុងមាត្រា១ នៃអនុក្រឹត្យលេខ ១៥ ដល់លេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការ វិនិយោគខេត្ត-ក្រុង នូវសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- | តំណាងខ័ណ្ឌរដ្ឋបាលព្រៃឈើ | សមាជិក |
| ២- | តំណាងខ័ណ្ឌរដ្ឋបាលជលផល | សមាជិក |

**មាត្រា២:** កែសំរួលពាក្យពេចន៍មួយចំនួនក្នុងអនុក្រឹត្យលេខ១៥ ដល់លេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង និងអនុក្រឹត្យកែសំរួលលេខ៨៩ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ដូចខាងក្រោម :

- សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានអានថា : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបានអានថា : រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**មាត្រា៣:** ក្រៅពីការកែសំរួលដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ខ្លឹមសារផ្សេងៗទៀតនៃអនុក្រឹត្យលេខ១៥ ដល់លេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង និងអនុក្រឹត្យកែសំរួលលេខ៨៩ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ នៅមានសុពលភាពអនុវត្តដដែល ។

**មាត្រា៤ :** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី -រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ -រដ្ឋមន្ត្រីគ្រប់ក្រសួង -អភិបាលគ្រប់ខេត្ត/ក្រុង -គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ចម ប្រសិទ្ធ**

លេខ : ០៥៤ ពណ.រប.ចល

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក**

- ថ្នាក់ដឹកនាំក្រសួង " មេត្តាជ្រាប "
- អគ្គនាយកដ្ឋាន-អគ្គាធិការដ្ឋាន , ខុទ្ទកាល័យ និងគ្រប់នាយកដ្ឋានក្រោមឪវាទក្រសួង
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៦

តប.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រធាននាយកដ្ឋានរដ្ឋបាល

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន"ក.អ.ក"
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ